# គម្រោងរេដបូកសំកុស
# លេខអត្តសញ្ញាណគម្រោងៈ ៣៣៤១
# សង្ខេបសេចក្តីបរិយាយនៃគម្រោង

ដោយមានគោលបំណងជួយរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវគោលដៅបរិស្ថានសម្រាប់កំណើនសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព ដើម្បីជួយជំរុញឲ្យមានការកាត់បន្ថយ និងការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ អភិរក្សជីវចម្រុះ និងបង្កើតឲ្យមានជម្រើសជីវភាពរស់នៅ ស្របតាមផែនការរបស់អង្គការសហប្រជាជាតិ ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ និងរេចរិលព្រៃឈើ) រេដបូក( អង្គការសម្ព័ន្ធមិត្តសត្វព្រៃ )Wildlife Alliance) និង Wildlife Works បានបង្កើតគម្រោងរេដបូកសំកុស(SRP)ឡើង ។ គម្រោងនេះគ្របដណ្តប់តំបន់ការពារធម្មជាតិចំនួនបីរួមមានៈ ដែនជម្រកសត្វព្រៃភ្នំសំកុស ជាតំបន់ការពារទេសភាព នៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ដែលគ្របដណ្តប់លើផ្ទៃដីសរុបទំហំ ២០២,៤៥១ហិកតា ច្រករបៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលមានផ្ទៃដីទំហំ ៨២,៧៣៥ ហិកតា និងតំបន់ភាគខាងជើងនៃឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូងស្ថិតនៅក្នុងខេត្តពោធិ៍សាត់ ដែលមានផ្ទៃដីទំហំ ១២,២១១ ហិកតា។ ផ្ទៃដីនៃតំបន់គម្រោងសរុបគឺ ២៩៧,៣៩៧ ហិកតា ហើយតំបន់ព្រៃឈើ និងតំបន់គណនេយ្យគម្រោងសរុបមានទំហំ ២៨២,៧១៨ ហិកតា ។

មានតំបន់ការពារធម្មជាតិចំនួនបីដែលរួមគ្នាបង្កើតបានជាគម្រោងរេដបូកសំកុសគឺជាផ្នែកដ៏សំខាន់នៃជួរភ្នំក្រវាញជាតំបន់សំបូរដោយជីវចម្រុះនៃឧបទ្វីបឥណ្ឌូ-ភូមា ។ តំបន់សំបូរដោយជីវចម្រុះនៃឧបទ្វីបឥណ្ឌូ-ភូមានេះ គឺទីកន្លែងដ៏សំខាន់ជាងគេមួយក្នុងចំណោមទីកន្លែងអភិរក្សជីវចម្រុះដ៏សំខាន់ៗជាងគេជាច្រើនទីតាំងទៀតនៅលើភពផែនដី ។ បើយោងតាមអង្គការអោយ-យូ-ស៊ី-អិន តំបន់នេះជាប់ចំណាត់ថ្នាក់ជាទីតាំងទាំង ១០ ក្នុងចំណោមតំបន់ដែលសំបូរដោយជីវចម្រុះដែលមិនអាចជំនួសបាន ហើយក៏ជាទីតាំងស្ថិតក្នុងលំដាប់កំពូលទាំង ៥ កំពុងទទួលរងនូវការគំរាមកំហែងដោយសារតែមានតែ ៥% ប៉ុណ្ណោះ នៃជម្រកធម្មជាតិដែលនៅសេសសល់ ។

ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងដល់ដែនជម្រកសត្វព្រៃភ្នំសំកុស និងច្រករបៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញប្រព័ន្ធតំបន់ការពារធម្មជាតិ អង្គការសម្ព័ន្ធមិត្តសត្វព្រៃជាមួយក្រសួងបរិស្ថាន) MOE)បានសម្រេចបង្កើតគម្រោងរេដបូកសំកុសនេះឡើង ។ ការការពារគម្រោងរេដបូកសំកុសនេះនឹងត្រូវសម្រេចបានដោយការរចនា និងផ្តល់នូវប្រព័ន្ធគ្រប់គ្រងសកម្ម ជាពិសេសសម្រាប់ដែនជម្រកសត្វព្រៃភ្នំសំកុស ដែលរួមមានការល្បាតផ្ទាល់របស់ឧទ្យាននៅតាមតំបន់គម្រោង និងខាងក្នុងតំបន់គណនេយ្យគម្រោង។ អង្គការសម្ព័ន្ធមិត្តសត្វព្រៃ និងឧទ្យានុរក្សរបស់ក្រសួងបរិស្ថានបានល្បាតតំបន់ធំ ៗ នៅក្នុងតំបន់គណនេយ្យគម្រោងរួចហើយ ចាប់តាំងពីឆ្នាំ ២០១៩ ដោយសារដែនជម្រកនេះមានព្រំប្រទល់ជាប់នឹងគម្រោងរេដបូកតំបន់ជួរភ្នំក្រវាញខាងត្បូង (ជាគម្រោង VCS មានលេខអត្តសញ្ញាណកម្ម ID 1748) ។

វិធីសាស្ត្រគោលក្នុងការកំណត់អត្តសញ្ញាណនៃអ្នកពាក់ព័ន្ធនៅក្នុងគម្រោងរេដបូកសំកុសគឺតាមរយៈសិក្ខាសាលាស្តីពីហេតុប៉ះពាល់សង្គមដែលបានប្រព្រឹត្តទៅនៅក្រុងពោធិ៍សាត់ ពីថ្ងៃទី១១ ដល់១៣ ខែតុលា ឆ្នាំ២០២២ ។ សិក្ខាសាលានេះមានអ្នកចូលរួមចំនួន ៦០ រូបដែលត្រូវកំណត់អត្តសញ្ញាណដោយអ្នកជំនាញជាតិ មានដូចជាអ្នកដឹកនាំ ឬតំណាងក្រុមអ្នកដែលពាក់ព័ន្ធជាមួយគម្រោង ។ លើសពីនេះទៀត ចំណេះដឹងនៃអ្នកជំនាញអំពីម្ចាស់គម្រោងត្រូវបានប្រើប្រាស់

ក្នុងការកំណត់អត្តសញ្ញាណអ្នកដែលពាក់ព័ន្ធផ្សេងទៀតដែលមិនទាន់បានកំណត់អត្តសញ្ញាណនៅឯសិក្ខាសាលាស្តីពីហេតុប៉ះពាល់សង្គម ។

នៅក្នុងតំបន់គម្រោងរួមមាន ២៧ភូមិ ស្ថិតក្នុង ៩ឃុំ, ៤ស្រុក និង ២ខេត្ត ។ នៅក្នុងសហគមន៍ដែលកំពុងលូតលាស់នេះមានប្រជាពលរដ្ឋរស់នៅចំនួន ៧,៩៥៣ គ្រួសារ ស្មើនឹងប្រជាពលរដ្ឋចំនួន ៣៤,១៧៩ នាក់ ដែលនេះជាការគំរាមកំហែងដ៏ធំមួយចំពោះគម្រោងរេដបូកសំកុស ។ ការគំរាមកំហែងនេះស្តែងចេញឲ្យឃើញជាទម្រង់នៃការកាប់រានដីព្រៃខុសច្បាប់ ការទន្ទ្រានចាប់យកដី ការកាប់ឈើខុសច្បាប់ ការរៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមិនបានល្អ ។

គម្រោងនេះក៏បាននឹងបង្កើតឱកាសចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព បង្កើតជម្រើសសកម្មភាពបង្កើតប្រាក់ចំណូល) IGAs) និងគំនិតផ្តួចផ្តើមដើម្បីជំរុញការវិនិយោគនៅក្នុងអាជីវកម្មមូលដ្ឋានដែលត្រូវបានរចនាឡើងដើម្បីកាត់បន្ថយសម្ពាធទៅលើបរិស្ថាន ដោយព្រមពេលជាមួយគ្នានោះបង្កើនសុខុមាលភាពសហគមន៍ផងដែរ ។ គម្រោងនេះនឹងបានរួមចំណែកជួយដោះស្រាយបញ្ហាសន្តិសុខស្បៀង/អាហារូបត្ថម្ភ និងហេដ្ឋារចនាសម្ព័ន្ធមានដូចជាអណ្តូងទឹក ជាដើម ។

អង្គការសម្ព័ន្ធមិត្តសត្វព្រៃបាននិងកំពុងជួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងតំបន់ទេសភាពព្រៃរងទឹកភ្លៀងជួរភ្នំក្រវាញចាប់តាំងពីឆ្នាំ ២០០២ មក ។ សកម្មភាពស្នូលរបស់អង្គការសម្ព័ន្ធមិត្តសត្វព្រៃរួមមានការល្បាតការពារព្រៃឈើ និងផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាលដើម្បីអនុវត្តការការពារព្រៃឈើ ។ អង្គការសម្ព័ន្ធមិត្តសត្វព្រៃក៏បានអនុវត្តសកម្មភាពអភិវឌ្ឍសហគមន៍ និងកម្មវិធីអប់រំផ្សព្វផ្សាយ ដើម្បីជួយសហគមន៍មូលដ្ឋាន ឲ្យធ្វើការផ្លាស់ប្តូរជីវភាពរស់នៅរបស់ខ្លួន ឲ្យមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការប្រើប្រាស់ធនធានធម្មជាតិដ៏សម្បូរបែប នៅក្នុងតំបន់ ប្រកបដោយនិរន្តភាពផងដែរ ។

តែទោះបីជាព្រៃឈើតំបន់នេះមានសារៈសំខាន់ដ៏ធំធេងបែបនេះក្តី តែការប្រែក្លាយដីព្រៃឈើជាទ្រង់ទ្រាយតូចៗឲ្យទៅជាដីកសិកម្មដែលគ្មានការត្រួតពិនិត្យគ្រប់គ្រង ធ្វើឡើងដោយជនចំណូលថ្មី និងការប្រែក្លាយដីព្រៃឈើឲ្យទៅជាចម្ការកសិ-ឧស្សាហកម្មដោយវិស័យឯកជន បានធ្វើឲ្យតំបន់ជួរភ្នំក្រវាញស្ថិតក្នុងចំណោមតំបន់ទេសភាពព្រៃឈើដែលកំពុងទទួលរងនូវការគំរាមកំហែងខ្លាំងជាងគេ នៅអាស៊ីអគ្នេយ៍ ។ សហគមន៍ប្រជាពលរដ្ឋនៅតាមទីជនបទរស់នៅអាស្រ័យទៅលើការផលិតផលកសិកម្មខ្នាតតូច ដើម្បីគាំទ្រជីវភាពរស់នៅរបស់ខ្លួន ។ កង្វះឱកាសការងារសម្រាប់ប្រជាពលរដ្ឋ ដែលកំពុងតែមានចំនួនកើនឡើង រួមផ្សំនឹងកង្វះចំណេះដឹងក្នុងការកែលំអបច្ចេកទេសធ្វើកសិកម្ម បានធ្វើឲ្យប្រជាពលរដ្ឋមូលដ្ឋានកាប់ឆ្ការព្រៃ ដើម្បីដាំដំណាំពាណិជ្ជកម្ម ។

ដើមហេតុចំបងដែលនាំឲ្យមានការកាប់បំផ្លាញព្រៃឈើគឺដោយសារតែមានតម្រូវការដីច្រើនសម្រាប់ធ្វើកសិកម្ម និងដាំដំណាំពាណិជ្ជកម្ម នៅក្នុងទីតាំងគម្រោងរេដបូកសំកុស ។ ចំនួនមនុស្សនៅក្នុងខេត្ត និងនៅក្នុងតំបន់បានកើនឡើងយ៉ាងច្រើនគួរឲ្យកត់សម្គាល់ ក្នុងរយៈមួយទសវត្សចុងក្រោយនេះ ។ កំណើនចំនួនមនុស្សគឺបណ្តាលមកពីជនចំណូលថ្មី និងអត្រាកំណើតរបស់កុមារនៅក្នុងភូមិដែលនៅជុំវិញ ។ បច្ចុប្បន្ននេះ ចំណេះដឹងមូលដ្ឋាននៅមានកម្រិតទាប ដោយសារតែតម្រូវការពលកម្មកុមារ ដើម្បីជួយការងារដាំដុះក្នុងគ្រួសារ នៅពេលថ្ងៃ ដែលបង្កើតឲ្យមានវដ្តនៃភាពក្រីក្រ ព្រមទាំងបង្កឲ្យមានការកាប់បំផ្លាញព្រៃឈើផងដែរ ។ ដើមហេតុផ្សេងទៀតដែលនាំឲ្យមានការកាប់បំផ្លាញព្រៃឈើផងដែរនោះ រួមមានការកាប់ឈើខុសច្បាប់ ដែលទាក់ទាញមនុស្សឲ្យចូលមកកាន់តំបន់នេះកាន់តែច្រើន និងការផលិតធ្យូង ។ សកម្មភាពទាំងនេះត្រូវបានប្រព្រឹត្តិឡើងជាពិសេសដោយសហគមន៍មូលដ្ឋាន ដើម្បីបានប្រភពចំណូលបន្ថែម ។

ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងទៅលើតំបន់ទេសភាពព្រៃរងទឹកភ្លៀងជួរភ្នំក្រវាញ អង្គការសម្ព័ន្ធមិត្តសត្វព្រៃរួមជាមួយក្រសួងបរិស្ថានបានសម្រេចបង្កើតជាគម្រោងរេដបូកសំកុសនេះឡើង ។ ការការពារគម្រោងរេដបូកសំកុសនឹងអាចសម្រេចទៅបានដរាបណានៅមានការបន្តការល្បាតពេញលេញនៅក្នុងតំបន់គម្រោង ក៏ដូចជាការផ្តល់នូវសកម្មភាពគម្រោងបន្ថែមដល់សហគមន៍ ដែលត្រូវបានត្រៀមរៀបចំឡើងបំណងកាត់បន្ថយដើមហេតុនៃការបាត់បង់ព្រៃឈើ ។ ក្នុងនេះមានសកម្មភាពគម្រោងចំបងចំនួនពីរគឺ ការធ្វើកសិកម្មពេញលេញ និងអណ្តូងទឹក ។ សកម្មភាពគម្រោងទាំងពីរនេះនឹងជួយឲ្យមានភាពប្រសើរឡើងនូវសុវត្ថិភាពផ្នែកហិរញ្ញវត្ថុរបស់ហគមន៍ ព្រមទាំងធ្វើឲ្យថយចុះនូវការដកហូតធនធានមកប្រើប្រាស់ដោយគ្មាននិរន្តភាព នៅក្នុងតំបន់គម្រោង ។

ផលប្រយោជន៍ផ្នែកអាកាសធាតុនៃគម្រោងរួមមានការកាត់បន្ថយការបញ្ចេញកាបោនក្នុងបរិមាណជាមធ្យមចំនួន ១,៩១១,៨២៣ តោននៃសមមូលកាបូនឌីអុកស៊ីតក្នុងមួយឆ្នាំ និងសរុបមានបរិមាណចំនួន ៥៧,៣៥៤,៦៩០ តោននៃសមមូលកាបូនឌីអុកស៊ីត នៅក្នុងដំណាក់កាលទាំងមូលនៃអាយុគម្រោងដែលមានរយៈពេល ៣០ ឆ្នាំ។ គម្រោងនឹងបង្កើតឲ្យមានសហអត្ថប្រយោជន៍ប្រកបដោយនិរន្តភាពទាំងសម្រាប់សហគមន៍ ទាំងជីវចម្រុះ ។ ឱកាសជីវភាពថ្មី និងប្រកបដោយនិរន្តភាព ដូចជា ការផ្តល់ការងារដោយផ្ទាល់ ជម្រើសសកម្មភាពបង្កើតចំណូល និងការផ្តួចផ្តើមបណ្តុះគំនិតវិនិយោគផ្នែកធុរកិច្ច នឹងចាត់ចែងរៀបចំដើម្បីកាត់បន្ថយសំពាធទៅលើបរិស្ថាន ព្រមពេលដែលសុខុមាលភាពរបស់សហគមន៍ត្រូវបានលើកកំពស់ឲ្យបានខុសប្លែកជាងពេលមុន។ កម្មវិធីបន្ថែមនឹងត្រូវបង្កើតឡើងដើម្បី ឆ្លើយតបទៅនឹងសុវត្ថិភាពស្បៀង កែលំអអាគារសម្ភារបម្រើវិស័យសុខាភិបាល និងអប់រំ ក៏ដូចជាការលើកកំពស់ការយល់ដឹងពីបរិស្ថាន ។

សហប្រយោជន៍ផ្នែកជីវចម្រុះនឹងត្រូវសម្រេចបានតាមរយៈការការពារកាន់តែតត់ហ្មត់នូវមជ្ឈដ្ឋានបរិស្ថាន ជាពិសេសតាមរយៈការបង្កើនសកម្មភាពល្បាត និងកែលំអការត្រួតពិនិត្យតាមដាន ។ គម្រោងក៏នឹងផ្តល់ការការពារទីជម្រកដ៏សំខាន់សម្រាប់ប្រភេទសត្វជាច្រើនប្រភេទដែលត្រូវបានចុះនៅក្នុងបញ្ជីអង្គការអោយ-យូ-ស៊ី-អិន មានដូចជា ដំរីអាស៊ី ខ្លាឃ្មុំធំ ខ្លាឃ្មុំតូច សំពោចធំ ខ្លាពពក និងឆ្កែព្រៃ ក៏ដូចជាប្រភេទសត្វកំពុងទទួលរងការគំរាមកំហែងជិតផុតពូជដូចជា ក្រពើភ្នំជាដើម ។

សូមមេត្តាចូលទៅអានគេហទំព័ររបស់អង្គការសម្ព័ន្ធមិត្តសត្វព្រៃ – https://www.wildlifealliance.org/ និងទំព័រហ្វេសប៊ុក ឬក៏ការិយាល័យគម្រោងដើម្បីអានឯកសារគម្រោងពេញលេញ ។

| | |
|---|---|
| **ឈ្មោះគម្រោង** | គម្រោងរេដបូកសំកុស |
| **លេខអត្តសញ្ញាណគម្រោង** | ៣៣៤១ |
| **ទីតាំងគម្រោង** | ប្រទេសកម្ពុជា ខេត្តពោធិ៍សាត់ បាត់ដំបង និងកោះកុង |
| **ម្ចាស់គម្រោង** | រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបរិស្ថាន<br>មន្ត្រីទំនាក់ទំនង: ជួប ប៉ារីស៍<br>អ៊ីម៉ែល: paris.ncg@gmail.com<br>ទូរស័ព្ទលេខ: ០១៧ ៣១៣ ៣៦៦ |

| | |
|---|---|
| **សវនករ** | អេស-ស៊ី-អេស គ្លូបល សើវីស៊ីស (SCS Global Services)<br>មន្ត្រីទំនាក់ទំនង: Christie Pollet-Young<br>អ៊ីម៉ែល: CPollet-Young@scsglobalservices.com<br>ទូរស័ព្ទលេខ: +៥១០.៩៩៣.០១២៤ |
| **កាលបរិច្ឆេទគម្រោងចាប់ផ្តើម, ដំណាក់កាលគណនេយ្យឧស្ម័នផ្ទះកញ្ចក់ និងអាយុគម្រោង** | កាលបរិច្ឆេទគម្រោងចាប់ផ្តើម: ០១ កញ្ញា ២០១៩<br>ដំណាក់កាលគណនេយ្យឧស្ម័នផ្ទះកញ្ចក់: ០១ កញ្ញា ២០១៩ ៣១ -កញ្ញា ២០៤៩<br>អាយុគម្រោង: ០១ កញ្ញា ២០១៩ ៣១ -កញ្ញា ២០៤៩ |
| **ដំណាក់កាលអនុវត្តគម្រោង** | ០១ កញ្ញា ២០១៩ - ៣១ ធ្នូ ២០២២ |
| **ប្រភេទនៃការវាយតម្លៃ** | នេះគឺជាការវាយតម្លៃ និងការផ្ទៀងផ្ទាត់ពេញលេញ |
| **ប្រវត្តិនៃស្ថានភាពការបោន សហគមន៍ ជីវចម្រុះ )CCB(** | នេះគឺជាការវាយតម្លៃគម្រោងលើកទីមួយ និងជាការផ្ទៀងផ្ទាត់គម្រោងលើកទីមួយ |
| **ការបោះពុម្ពផ្សាយនៃស្តង់ដារការបោន សហគមន៍ ជីវចម្រុះដែលកំពុងត្រូវបានយកមកប្រើប្រាស់សម្រាប់ការវាយតម្លៃនេះ** | គម្រោងនេះត្រូវបានកំពុងវាយតម្លៃ ក្រោមស្តង់ដារការបោន សហគមន៍ ជីវចម្រុះ ការបោះពុម្ពផ្សាយលើកទីបី |
| **កម្រិតមាសនៃលក្ខណៈវិនិច្ឆ័យ** | លក្ខណៈវិនិច្ឆ័យកម្រិតមាសពីរជាន់អាកាសធាតុ និងជីវចម្រុះ , |
| **កាលបរិច្ឆេទបញ្ចប់ និងលេខទម្រង់របស់ឯកសាររចនាគម្រោង** | កាលបរិច្ឆេទ: ៣ ឧសភា ២០២៣<br>ទម្រង់: ២០. |
| **សហគមន៍ ក្រុមសហគមន៍ និងអ្នកពាក់ព័ន្ធគម្រោងដែលបានកំណត់អត្តសញ្ញាណ** | **ភូមិ-ឃុំដែលគម្រោងបានកំណត់អត្តសញ្ញាណ៖** (១) អូរនេនោង, (២) អូរក្រូច, (៣) អូរត្រែង, (៤) ពាមតា, (៥) ពាម, (៦) អូរតាទាក, (៧) តាតោក, (៨) វាលរលឹម, (៩) ភ្នំរៃ, (១០) អូរជើមចេក, (១១) អូរជាំលើ, (១២) ព្រៃធំ, (១៣) សំពោង, (១៤) សំឡាញ, (១៥) ក្រពើពីរលើ, (១៦) កណ្តាល, (១៧) ក្រាំងរងៀង, (១៨) ចំការជ្រៃខាងជើង, (១៩) ចំការជ្រៃខាងត្បូង, (២០) ដីក្រហម, (២១) ឈើទាលជ្រុំ, (២២) ថ្លឹកជ្រុំ, (២៣) ទំពរ, (២៤) ក្បែត្របូរី, (២៥) តាដេះ, (២៦) វាល<br><br>**ក្រុមសហគមន៍/អ្នកពាក់ព័ន្ធ៖** អ្នកកាប់ឈើ ព្រានព្រៃ អ្នកជួញដូរឈើ អ្នកជួញដូរសត្វព្រៃ អ្នករកស៊ីកេងប្រវ័ញ្ចយកចំណេញលើដី អ្នកប្រមូលអនុផលព្រៃឈើ អ្នកធ្វើការផ្នែកមីក្រូហិរញ្ញវត្ថុ ម្ចាស់បំណុល សហគមន៍មូលដ្ឋាន រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន យុវជន និងស្ត្រី កម្មករ/អ្នករកការងារធ្វើ អ្នកខ្ចីលុយ និងកូនបំណុល |

# ផែនទីតំបន់គម្រោង និងតំបន់សហគមន៍នៃគម្រោងរេដបូកសំកុស

